# ប្រទេសកម្ពុជាក្រោមការពិនិត្យឡើងវិញនៃអនុសញ្ញាស៊ី-ដ៖ សិទ្ធិស្ត្រីនៅកម្ពុជា

ចាប់ពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ប្រទេសកម្ពុជាត្រូវបានពិនិត្យឡើងវិញដោយគណៈកម្មាធិការស៊ី-ដ ក្នុងសម័យប្រជុំលើកទី៧៤ របស់ខ្លួនទៅលើការអនុវត្តសិទ្ធិស្ត្រីដែលបានចែងនៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(ស៊ី-ដ)។ សូមមើលទៅលើទិដ្ឋភាពទូទៅនៃស្ថានភាពសិទ្ធិស្ត្រីនៅកម្ពុជា និងអនុសាសន៍របស់យើងដែលបានដាក់ជូនទៅកាន់រាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើការកែលម្អចំពោះការរំលោភបំពានសិទ្ធិស្ត្រីឱ្យកាន់តែប្រសើរឡើង ។

## ច្បាប់

នៅក្នុងទ្រឹស្តី ស្ត្រីនៅកម្ពុជាមានសិទ្ធិស្មើនឹងបុរសនៅចំពោះមុខច្បាប់ ប៉ុន្តែការអនុវត្តជាក់ស្តែងស្ត្រីមិនទាន់ទទួលបាននូវសមភាពរវាងបុរស និងស្ត្រីពេញលេញនៅឡើយទេ។

**រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាចែងថា៖**

- ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ដោយឥតប្រកាន់ភេទឡើយ (មាត្រា ៣១)
- ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ និងការធ្វើអាជីវកម្មទៅលើការងាររបស់ស្ត្រីត្រូវលុបបំបាត់ចោល (មាត្រា ៤៥)
- ស្ត្រីមានសិទ្ធិស្មើគ្នានៅគ្រប់វិស័យទាំងអស់ដោយរួមបញ្ចូលទាំងសិទ្ធិជ្រើសរើសគូស្រករ (មាត្រា ៤៥)

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា៖**

- រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងការប្រើប្រាស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដូចមានចែងនៅក្នុងកតិកាសញ្ញានេះ (មាត្រា ៣) ។

**អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទបានបញ្ជាក់យ៉ាងច្បាស់ថា៖**

- រដ្ឋភាគីគួរថ្កោលទោសចំពោះការរើសអើងប្រឆាំងនឹងនារីភេទក្នុងគ្រប់ទម្រង់ និងព្រមព្រៀងគ្នាអនុវត្តគោលនយោបាយតាមមធ្យោបាយសមស្រប និងដោយឥតមានការពន្យាពេល ដើម្បីឈានទៅលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ (មាត្រា ២)

## ការងារ

នៅកម្ពុជា ស្ត្រីដែលធ្វើការនៅក្នុងវិស័យកាត់ដេរ និងវិស័យសំណង់គឺមានភាគរយខ្ពស់។ ភាគច្រើនកម្មករទាំងនោះគឺជាជនចំណាកស្រុក និងងាយទទួលរងនូវការធ្វើទុក្ខបុកម្នេញផ្សេងៗ។

- ស្ត្រីមិនមានភាពជាតំណាងរបស់ខ្លួននៅក្នុងថ្នាក់ដឹកនាំសហជីពដែលនេះអាចបណ្តាលឱ្យមានគម្លាតប្រាក់ឈ្នួល និងលក្ខខណ្ឌសុខភាព និងសុវត្ថិភាពមានកម្រិតទាបសម្រាប់កម្មករ។
- ការប្រើប្រាស់កិច្ចសន្យារយៈពេលខ្លីលើសពីពីរឆ្នាំ គឺជាការរំលោភបំពានដោយផ្ទាល់ទៅលើច្បាប់ការងារកម្ពុជា។ ប៉ុន្តែ បញ្ហានេះនៅតែកើតមានឡើងនៅក្នុងស្ថានភាពជាក់ស្តែង។ កិច្ចសន្យាទាំងនេះធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើការងាររបស់ស្ត្រី ដោយសារតែហានិភ័យនៃការមិនបន្តកិច្ចសន្យាថ្មីនៅពេលដែលកម្មការនីមានផ្ទៃពោះ ឬចូលរួមសកម្មភាពជាមួយសហជីពជាដើម។

**អនុសាសន៍** ៖ កែសម្រួលជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ដើម្បីដាក់ទណ្ឌកម្មទៅលើនិយោជកដែលជួលកម្មការនីខុសច្បាប់ដោយប្រើកិច្ចសន្យារយៈពេលខ្លី បន្ទាប់ពីរយៈពេលអតិបរិមាចំនួនពីរឆ្នាំ។

## ភាពជាតំណាងក្នុងវិស័យនយោបាយ



បើទោះបីជារាជរដ្ឋាភិបាលកម្ពុជានៅតែបន្តយកចិត្តទុកដាក់ទៅលើគោលការណ៍ស្ម័គ្រចិត្តក្នុងការបង្កើនចំនួនស្ត្រីនៅក្នុងជួរមន្ត្រីរាជការ និងនយោបាយក៏ដោយ ក៏តំណាងស្ត្រីនៅតែមិនទាន់គ្រប់គ្រាន់ក្នុងកម្រិតការសម្រេចចិត្ត ជាពិសេសនៅក្នុងវិស័យនយោបាយ និងជួររដ្ឋាភិបាល ។

- មិនមានកាតព្វកិច្ចផ្នែកច្បាប់ ឬការគាំទ្រផ្នែកថវិកាសម្រាប់តំណាងស្ត្រីក្នុងវិស័យនយោបាយនៅថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិនោះទេ ហេតុដូច្នេះហើយគោលដៅនៃការស្ម័គ្រចិត្តទាំងនេះ តែងតែគ្មានប្រសិទ្ធភាពក្នុងការអនុវត្តឱ្យបានសម្រេច។
- បើទោះជាមិនមានការរើសអើងប្រឆាំងនឹងស្ត្រីភេទក៏ដោយ ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែង ស្ត្រីភាគច្រើនមិនត្រូវបានរាប់បញ្ចូលក្នុងដំណើរការនយោបាយ ដោយសារមានលក្ខខណ្ឌតម្រូវរបស់គណបក្សនយោបាយ ឬមន្ត្រីរដ្ឋាភិបាលក្នុងការតែងតាំងបុគ្គលណាមួយ។

**អនុសាសន៍** ៖ ត្រូវអនុម័តវិធានការច្បាប់ និងវិធានការជាក់ស្តែងឱ្យបានម៉ឺងម៉ាត់ដើម្បីធានាថានៅឆ្នាំ២០២៣ យ៉ាងហោចណាស់ក៏មានស្ត្រី ចំនួន ៣៥ ភាគរយនឹងទទួលបានមុខតំណែងក្នុងការសម្រេចចិត្តក្នុងជួររដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ រាល់វិធានការចាំបាច់ទាំងអស់នឹងត្រូវធ្វើឡើង ដើម្បីធានាថាថ្នាក់ដឹកនាំជាស្ត្រីពិតជាមានឯករាជ្យភាព និងអាចធ្វើសកម្មភាពដោយប្រើសិទ្ធិអំណាចផ្ទាល់ខ្លួនក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

## ការអប់រំ

ប្រទេសកម្ពុជាមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ ក្នុងការដោះស្រាយគម្លាតក្នុងវិស័យអប់រំរវាងក្មេងប្រុស និងក្មេងស្រី។ ទោះបីជាយ៉ាងនេះក្តី ការចូលសាលារៀននៅតែមិនមែនជាកាតព្វកិច្ចចាំបាច់សម្រាប់កុមារនៅកម្ពុជា ហើយក៏មិនមានការលើកទឹកចិត្តឪពុកម្តាយឲ្យបញ្ជូនកូនស្រីមកចូលរៀននោះដែរ។

- ចំពោះស្ត្រីដែលបោះបង់ការសិក្សាលឿនពេកភាគច្រើនទទួលបានការងារនៅក្នុងមុខតំណែងដែលមានប្រាក់កម្រៃទាប។
- កុមារីដែលមានពិការភាពជារឿយៗត្រូវបានឱ្យស្នាក់នៅក្នុងផ្ទះ។ កង្វះការអប់រំ និងទំនាក់ទំនងជាមួយមនុស្សផ្សេងទៀត ធ្វើឱ្យស្ត្រីដែលមានពិការភាពងាយទទួលរងគ្រោះផ្នែកសេដ្ឋកិច្ច។

**អនុសាសន៍** ៖ ធ្វើឱ្យការអប់រំក្លាយជាកាតព្វកិច្ចចាំបាច់សម្រាប់កុមារទាំងអស់។ នេះរួមបញ្ចូលទាំងការធានាបានថាក្មេងស្រីដែលមានពិការភាពទាំងអស់ត្រូវបានចុះឈ្មោះចូលរៀន ហើយសិស្សដែលមានពិការភាពដែលពិបាកក្នុងការចល័តក៏អាចចូលរៀននៅសាលាដូចគ្នាផងដែរ។

## អំពើហិង្សាទាក់ទងនឹងយេនឌ័រ

រាជរដ្ឋាភិបាលកម្ពុជាត្រូវបានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការលើកកម្ពស់ការយល់ដឹងអំពីហិង្សាក្នុងគ្រួសារដែលជាអំពើខុសច្បាប់។ ប៉ុន្តែគ្រប់ទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតែបន្តកើតមានឡើង។

- ច្បាប់ដែលពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រគឺនៅមានភាពទន់ខ្សោយ ដែលជាហេតុនាំឲ្យមានឧបសគ្គក្នុងការបញ្ឈប់អំពើហិង្សាលើស្ត្រី។
- កង្វះខាតសេវាសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ឧទាហរណ៍៖ បណ្តាញទូរស័ព្ទបន្ទាន់របស់រដ្ឋ ដើម្បីរាយការណ៍បញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រមិនដំណើរការ ហើយក៏មិនមានការជួយសម្រួលឱ្យមានជម្រកសុវត្ថិភាពពីខាងរដ្ឋាភិបាលនៅទូទាំងប្រទេសផងដែរ។

**អនុសាសន៍**៖ ធានាបង្កើតឱ្យបាននូវការិយាល័យច្រកចេញចូលតែមួយដើម្បីផ្តល់សេវាគាំទ្រទៅដល់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រដោយឥតគិតថ្លៃ។

សម្រាប់ព័ត៌មានបន្ថែម សូមមើលរបាយការណ៍ស្រមោលរបស់អង្គការសង្គមស៊ីវិល បន្ថែមទៅលើរបាយការណ៍អំពី ស៊ី-ដ របស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈ ៖ http://bit.ly/2D6SNYM

ឧបត្ថម្ភដោយ

EUROPEAN UNION

DCA actalliance

ផលិតដោយ

VOICES for GENDER EQUALITY

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

@CCHRCambodia @CCHRCambodia @EU.Cambodia

BY NC SA

ខែមិថុនា ឆ្នាំ២០២០